ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ០៦៦.........សហវ.ប្រក.អថ

# ប្រកាស
## ស្តីពី
## ការបង្កើត និងការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពត្រួតពិនិត្យថវិកា នៅអមក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- ប្រកាសលេខ ០៦២ សហវ.ប្រក.អថ ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០២៤ ស្តីពីសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អភិបាលថវិកា
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ត្រូវបានបង្កើតអង្គភាពត្រួតពិនិត្យថវិកា សរសេរជាអក្សរកាត់ "អ.ត.ថ." ឱ្យនៅអមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ដើម្បីបំពេញមុខងារត្រួតពិនិត្យការអនុវត្តថវិកា ។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពត្រួតពិនិត្យថវិកា ដែលនៅអមក្រសួង ស្ថាប័ន និង អង្គភាពសាធារណៈប្រហាក់ប្រហែល ។

## ជំពូកទី ២

## រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច

**ប្រការ៣.-**

អ.ត.ថ. ត្រូវស្ថិតក្រោមការគ្រប់គ្រងមុខងាររបស់នាយកដ្ឋានហិរញ្ញកិច្ចនៃអគ្គនាយកដ្ឋានថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

អ.ត.ថ. ត្រូវដឹកនាំដោយប្រធាន ១ (មួយ) រូប ដែលមានឋានៈនិងបុព្វសិទ្ធិស្មើនឹងអនុប្រធាននាយកដ្ឋាន និងអាចមានអនុប្រធានមួយចំនួនតាមការចាំបាច់ ដែលមានឋានៈនិងបុព្វសិទ្ធិស្មើនឹងប្រធានការិយាល័យ ។

ប្រធាន និងអនុប្រធាន ព្រមទាំងមន្ត្រី នៃ អ.ត.ថ. ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ៤.-**

អ.ត.ថ. មានតួនាទីនិងភារកិច្ចដូចតទៅ ៖

- ត្រួតពិនិត្យនិងតាមដានការអនុវត្តចំណាយចរន្តឱ្យស្របតាមបទប្បញ្ញត្តិជាធរមាន
- តាមដាននិងជំរុញការអនុវត្តចំណូលមិនមែនសារពើពន្ធ ស្របតាមបទប្បញ្ញត្តិជាធរមាន
- ផ្តល់យោបល់និងជំរុញក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទ ក្នុងការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ក្នុងគោលបំណងគោរពឱ្យបានហ្មត់ចត់នូវគោលការណ៍និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងវិន័យថវិកា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន ដើម្បីលើកកម្ពស់ប្រសិទ្ធភាពជំនាញវិជ្ជាជីវៈ និងប្រសិទ្ធភាពចំណាយ
- ផ្តល់ទិដ្ឋាការធានាចំណាយ និងអាណត្តិបើកប្រាក់ទៅតាមមុខសញ្ញាចំណាយ តាមកម្រិតទឹកប្រាក់ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុប្រគល់សិទ្ធិ
- រៀបចំផ្តល់យោបល់ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុពិនិត្យ និងសម្រេច លើសំណើចំណាយសម្រាប់មុខសញ្ញាចំណាយដែលមិនស្ថិតក្រោមសិទ្ធិ និងការទទួលខុសត្រូវរបស់ខ្លួន
- ផ្តល់យោបល់លើកម្មវិធីចំណូល-ចំណាយ និងការអនុវត្តសមិទ្ធកម្ម របស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល
- ពិនិត្យ និងតាមដានរបាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) និងរបាយការណ៍សមិទ្ធកម្មដែលរៀបចំដោយក្រសួង ស្ថាប័នសាមី

- ចូលរួមរៀបចំផែនការយុទ្ធសាស្ត្រថវិការយៈពេលមធ្យម និងផែនការថវិកាប្រចាំឆ្នាំ
- ជានាអនុលោមភាពការអនុវត្តថវិកាជាមួយនឹងស្មារតីនៃកិច្ចប្រជុំការពារគម្រោងថវិកាប្រចាំឆ្នាំ
- ពិនិត្យនិងផ្តល់យោបល់លើការស្នើសុំចលនាឥណទាន
- ចូលរួមក្នុងកិច្ចប្រគល់-ទទួលទំនិញ សម្ភារៈ បរិក្ខារ សេវា និងសំណង់ តាមនីតិវិធីជាធរមាន
- រៀបចំរបាយការណ៍អនុវត្តថវិកា (ចំណូល-ចំណាយ) ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័នទទួលបន្ទុក តាមគំរូ ដោយផ្ទៀងផ្ទាត់តួលេខឱ្យបានត្រឹមត្រូវជាមួយសាមីក្រសួង ស្ថាប័ន ព្រមទាំងរៀបចំរបាយការណ៍សកម្មភាពរបស់ខ្លួន ជូនថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម
- បំពេញភារកិច្ចផ្សេងទៀតតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

## ជំពូកទី ៣
## របៀបរបបការងារ

**ប្រការ៥.-**

អ.ត.ថ. ពិនិត្យសំណើសុំចំណាយរបស់ក្រសួង ស្ថាប័ន ទៅតាមមុខសញ្ញាចំណាយ និងតាមកម្រិតទឹកប្រាក់ តាមការប្រគល់សិទ្ធិពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងផ្តល់យោបល់ឱ្យបានសមហេតុផលជាលាយលក្ខណ៍អក្សរ តាមរយៈកំណត់បង្ហាញរឿង ដូចតទៅ ៖

១- ពិនិត្យនិងផ្តល់យោបល់ ព្រមទាំងផ្តល់ទិដ្ឋាការធានាចំណាយ និង/ឬអាណត្តិបើកប្រាក់ ក្នុងរយៈពេលយ៉ាងយូរ៣ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីបញ្ជាក់ពីការយល់ព្រមឱ្យអនុវត្តចំណាយ ដោយអនុលោមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន ។ ក្នុងករណីពិនិត្យឃើញថាសំណើចំណាយមានវេទយិតភាព មន្ត្រីត្រួតពិនិត្យថវិកាត្រូវស្នើសុំការសម្រេចពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។

២- ក្នុងករណីពិនិត្យឃើញមានកំហុសឆ្គង ឬភាពមិនច្បាស់លាស់ អ.ត.ថ. ត្រូវស្នើសុំការកែតម្រូវ ការបញ្ជាក់ ឬការពន្យល់បន្ថែមពីសាមីក្រសួង ស្ថាប័ន ។ ប្រសិនបើការកែតម្រូវ ការបញ្ជាក់ ឬការពន្យល់អាចដោះស្រាយបាននូវបញ្ហាខុសឆ្គង ឬភាពមិនច្បាស់លាស់ អ.ត.ថ. ត្រូវអនុវត្តតាមចំណុចទី១ ខាងលើ ។ ក្នុងករណីការកែតម្រូវ ការបញ្ជាក់ ឬការពន្យល់បន្ថែមនេះ នៅតែមិនអាចឆ្លើយតបនឹងតម្រូវការទេ នោះ អ.ត.ថ. ត្រូវបញ្ជាក់ជាលាយលក្ខណ៍អក្សរអំពីការខ្វះខាតទាំងនោះ និងបញ្ជាក់អំពីការមិនយល់ព្រម និងមូលហេតុ ដើម្បីបញ្ជូនត្រឡប់ទៅសាមីក្រសួង ស្ថាប័នវិញ ព្រមទាំងត្រូវធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។

**ប្រការ៦.-**

អ.ត.ថ. ពិនិត្យសំណើសុំចំណាយរបស់ក្រសួង ស្ថាប័ន ដែលមានទឹកប្រាក់ធំជាងកម្រិតទឹកប្រាក់ដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រគល់សិទ្ធិ ដោយត្រូវផ្តល់យោបល់ឱ្យបានត្រឹមត្រូវជាលាយលក្ខណ៍អក្សរ ដើម្បីសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមឋានានុក្រម ។ រាល់ឯកសារដែលបញ្ជូនមករដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវមានសក្ខីបត្រភ្ជាប់គ្រប់គ្រាន់ និងត្រឹមត្រូវ ។

**ប្រការ៧.-**

អ.ត.ថ. ពិនិត្យនិងផ្តល់យោបល់លើកម្មវិធីចំណូល-ចំណាយ និងសំណើសុំនិយ័តភាពថវិការបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែល ក្នុងរយៈពេលបី (៣) ថ្ងៃនៃថ្ងៃធ្វើការ រួចបញ្ជូនទៅក្រសួង ស្ថាប័ន

និងអង្គភាពសាមី និងទៅនាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីមុខការបន្ត តាមការប្រគល់សិទ្ធិ ស្របតាមបទប្បញ្ញត្តិជាធរមាន ។

**ប្រការ៨.-**

អ.ត.ថ. ត្រូវរៀបចំរបាយការណ៍អនុវត្តថវិកា(ចំណូល-ចំណាយ), របាយការណ៍ផ្តល់ទិដ្ឋាការ ឬមិនផ្តល់ទិដ្ឋាការ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ របស់ក្រសួង ស្ថាប័ន ទទួលបន្ទុក តាមគំរូ និងពេលវេលាកំណត់ដោយបទដ្ឋានគតិយុត្តពាក់ព័ន្ធ ព្រមទាំងរបាយការណ៍ផ្សេងទៀតតាមការចាំបាច់ ។

## ជំពូកទី ៤
## សិទ្ធិអំណាច និងការទទួលខុសត្រូវ

**ប្រការ៩.-**

ប្រធាន អ.ត.ថ. អាចទទួលបានការប្រគល់សិទ្ធិជាអភិបាលថវិកាពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។

ប្រធាន អ.ត.ថ. ត្រូវប្រគល់សិទ្ធិជូនអនុប្រធានមួយរូបជាអភិបាលថវិកា ដើម្បីចាត់ចែងការងារ និងចុះហត្ថលេខាលើលិខិតផ្លូវការទាំងឡាយ ក្នុងករណីអវត្តមានឬមានធុរៈ ដោយមានការឯកភាពពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានានិរន្តភាពការងាររបស់ អ.ត.ថ. ។

ប្រធាន អ.ត.ថ. ត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវរាល់កិច្ចការរបស់ខ្លួន ។

**ប្រការ១០.-**

សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ប្រធាន អ.ត.ថ. និងការប្រគល់សិទ្ធិជាអភិបាលថវិកា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ។

**ប្រការ១១.-**

ក្នុងការបំពេញមុខងារដូចមានកំណត់ក្នុងប្រការ៩ និងប្រការ១០ នៃប្រកាសនេះ ប្រធាន អ.ត.ថ. មានសិទ្ធិប្រើប្រាស់ត្រាអភិបាលថវិកា ដែលរៀបចំដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការទទួលស្គាល់ដោយស្ថាប័នមានសមត្ថកិច្ច ។

## ជំពូកទី ៥
## ការលើកទឹកចិត្ត និងទណ្ឌកម្ម

**ប្រការ១២.-**

មន្ត្រីនៃ អ.ត.ថ. គ្រប់ឋានៈត្រូវទទួលបានការសរសើរ ចំពោះស្នាដៃជាគំរូក្នុងការបំពេញភារកិច្ចបានប្រសើរ ដោយផ្តល់ជាបណ្ណសរសើរ មេដាយ រង្វាន់ ឬដំឡើងថ្នាក់ ឋានន្តរស័ក្តិ ។ល។

**ប្រការ១៣.-**

មន្ត្រីនៃ អ.ត.ថ. គ្រប់ឋានៈត្រូវទទួលទណ្ឌកម្មរដ្ឋបាលតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន ដោយមិនទាន់គិតដល់ទណ្ឌកម្មព្រហ្មទណ្ឌ និងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីផ្សេងៗ ចំពោះសកម្មភាពដែលបានប្រព្រឹត្ត ឬសមគំនិតក្នុងការប្រព្រឹត្ត ។ ទណ្ឌកម្មរដ្ឋបាលទាំងនេះ មានដូចខាងក្រោម៖

- ការស្តីបន្ទោស
- ការផ្លាស់កន្លែងធ្វើការដោយបង្ខំតាមវិធានការខាងវិន័យ

- ការលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យនៅទំនេរគ្មានបៀវត្ស
- ការបន្ថយឋានន្តរស័ក្តិ ឬថ្នាក់
- ការដាក់ឱ្យចូលនិវត្តន៍មុនកាលកំណត់
- ការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីមុខតំណែងជាមន្ត្រីរាជការ ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍ ។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាននិងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ពុធ ១៤កើត ខែ បុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស. ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែ មករា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ដូចប្រការ១៥
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ